ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ០៧២៣ព.ណ ៩៧

ភ្នំពេញ, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹង ដល់ម្ចាស់សហគ្រាស ពាណិជ្ជករ អាជីវករ និងសាធារណជនទូទៅឲ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា នឹងរៀបចំពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៧ ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី១៤-១៦ ខែមេសា ឆ្នាំ២០១៧ នៅក្រុងសៀមរាប ខេត្តសៀមរាប។

ការរៀបចំព្រឹត្តិការណ៍នេះ ក្នុងគោលបំណងដើម្បីចូលរួមអបអរសាទរ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ និងជាឱកាសដែលយុវជន និងប្រជាពលរដ្ឋកម្ពុជា បានជួបជុំគ្នាក្នុងនាមជាមហាគ្រួសារខ្មែរតែមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស ពាណិជ្ជករ និងអាជីវករ ដែលមានបំណងទៅចូលរួមផ្សព្វផ្សាយ និងលក់ផលិតផលរបស់ខ្លួន ក្នុងព្រឹត្តិការណ៍នេះ សូមមកទំនាក់ទំនង និងបំពេញបែបបទនៅនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ។

ចំពោះព័ត៌មានលម្អិតផ្សេងៗ ស្ដីពីការរៀបចំពិព័រណ៍ខាងលើ សូមទំនាក់ទំនងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមទូរស័ព្ទលេខ ០៧៦ ៥៥៥ ៥៦៧៩/ ០៧៧ ៣៣៩ ៤៣៩/ ០៨៧ ៧៥៥ ៥៥១/ ០១២ ២៥៣ ៣៥៥/ ០១២ ៨៤២ ១១៩

អ៊ីម៉ែល៖sorn_pitou@yahoo.com, neary86@yahoo.com, rithyco@yahoo.com, sokdarith72@gmail.com

សូមអរគុណ!

ផ្ទះលេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ៖(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*